**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## ក្រសួងឧស្សាហកម្ម និងសិប្បកម្ម

កំពត-ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦៖ **ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម និង** ឯកឧត្តម ចាន់ ចេស្តា អភិបាលខេត្តកំពត រួមជាមួយនិងមន្ត្រីក្រោមឱវាទ បានចុះចែកទឹកស្អាតជូនប្រជាពលរដ្ឋនៅភូមិព្រានទុំ ឃុំស្រែជាខាងជើង ស្រុកដងទង់ ខេត្តកំពត ដែលកំពុងតែប្រឈមនឹងភាពរាំងស្ងួត ខ្វះខាតទឹកស្អាតប្រើប្រាស់។




មានប្រសាសន៍នាឱកាសនោះ **ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ** បានបញ្ជាក់ថាៈ ការចែកចាយទឹកនេះ គឺជាយុទ្ធនាការទូទាំងប្រទេស ដែលសម្តេចតេជោ នាយករដ្ឋមន្ត្រី បានធ្វើការណែនាំ ស្របពេលដែលភាពរាំងស្ងួត និងរលកកំដៅបានកើតឡើងមិនត្រឹមតែប្រទេសកម្ពុជាទេ គឺពាសពេញពិភពលោកនាឆ្នាំនេះ ។ ឯកឧត្តមទេរដ្ឋមន្ត្រី បានបន្ថែមថាៈ យុទ្ធនាការចែកចាយទឹកនេះ ឯកឧត្តម បានចេញបទបញ្ជាជាលេខល័ក្សអក្សររួចហើយដល់ថ្នាក់ដឹកនាំ និងមន្ទីរឧស្សាហកម្មខេត្ត រួមជាមួយរដ្ឋាករទឹកស្វយ័ត សហការជាមួយអាជ្ញាធរដែនដី ដើម្បី

អនុវត្តយុទ្ធនាការនេះឲ្យបានល្អប្រសើរជូនប្រជាពលរដ្ឋតាមតំបន់គោលដៅ ដែលកំពុងប្រឈមនិងការខ្វះខាតទឹក ។





ក្នុងនាម ជាប្រធានក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្តកំពត **ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ** បានថ្លែងអំណរគុណ ដល់**ក្រុមហ៊ុន ជីប ម៉ុង** ដែលបានជួយជារថយន្តដឹកទឹកចំនួន ០៥គ្រឿងសម្រាប់ជាមធ្យោបាយដឹកជញ្ជូនចែកចាយទឹក ហើយកំពុងពិនិត្យលទ្ធភាពជួយចំនួន ០៥ គ្រឿងទៀត ។ ទាក់ទងចំណុចនេះ **ឯកឧត្តមទេសរដ្ឋមន្ត្រី**បានអំពាវនាវដល់សប្បុរសជននានាបន្តជួយតាមលទ្ធភាពជាក់ស្តែង ជាពិសេសមានការខ្វះខាតរថយន្តដឹកជញ្ជូនទឹក ។











ស្ថិតក្នុងឱកាសនោះដែរ **ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ** បានណែនាំដល់មន្ត្រីជំនាញ រកទីតាំងសមស្របដែលមានប្រភពទឹក្រោមដី ដើម្បីខួងអណ្តូង បូមទឹក ចែកជូនប្រជាពលរដ្ឋ ដែលនៅឆ្ងាយពីប្រភពទឹក រឺមិនមានប្រព័ន្ធទឹកស្អាតចូលដល់ ។ ដែលដំណាក់កាលដំបូង ឯកឧត្តម បានសម្រេចឲ្យខួងអណ្តូងយកទឹកក្រោមដី នៅ

*រៀបចំដោយៈ នាយកដ្ឋានផែនការ ស្ថិតិ សហប្រតិបត្តិការ និងការងារអាស៊ាន*

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ស្រុកជងទុងមួយ និងស្រុកកំពង់ត្រាចមួយ បើលទ្ធផលល្អ នឹងអនុវត្តនៅទីតាំងស្រុកដ៏ទៃទៀត ដោយ ឯកឧត្តមនឹងចេញថវិកាផ្ទាល់ខ្លួន និងស្វែងរកប្រភពសប្បុរសជនខ្លះ ។






ប៉ុន្តែសម្រាប់ការផ្គត់ទឹកបន្តទៀតក្នុងយុទ្ធនាការនេះ ឯកឧត្តមស្នើឲ្យពិនិត្យលទ្ធភាពឲ្យបានខ្ពស់ជាងនេះ គឺបូមទឹកស្អាតពីអង្គភាពរដ្ឋាករទឹករដ្ឋ និង ឯកជន ដែលជាជំនួយឧបត្ថម្ភ ហើយបើលើសសមត្ថភាព យើងត្រូវចំណាយលុយទិញគាត់ថែម ។ ជាចុងក្រោយ ឯកឧត្តមទេសរដ្ឋមន្ត្រី បានកោតសរសើរចំពោះកិច្ចសហការគ្នាដ៏ល្អ ក្នុងចំណោមក្រុមការងារថ្នាក់ជាតិ ក៏ដូចជាក្រុមការងារបក្ស ក្នុងការចុះជួយប្រជាពលរដ្ឋគ្រប់ក្រុមគ្រួសារ ដែលកំពុងមានការខ្វះខាតទឹកប្រើប្រាស់ ក្នុងគោ…





*រៀបចំដោយ៖ នាយកដ្ឋានផែនការ ស្ថិតិ សហប្រតិបត្តិការ និងការងារអាស៊ាន*